**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែកនិងកាមរោគ**

# របាយការណ៍សកម្មភាពស្តីពីការអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ថ្ងៃទី ៣ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក របស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

## សម្រាប់សកម្មភាពថ្ងៃទី៣៖ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០២៣

ដោយទទួលបានការណែនាំ និងចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រោមការដឹកនាំដោយផ្ទាល់ដោយ **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នាថ្ងៃអាទិត្យ ១៤ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹង ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ត្រូវនឹងថ្ងៃទី៣ នៃយុទ្ធនាការក្រុមការងារមជ្ឈមណ្ឌលជាតិ និងអង្គការដៃគូពាក់ព័ន្ធបានបន្តយុទ្ធនាការផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍និងជំងឺអេដស៍ និងចុះចែកស្រោមអនាម័យដោយឥតគិតថ្លៃ ដល់កីឡាករអុំទូក និងដល់សាធារណជនដែលចូលរួមនៅក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ទៅតាមទីតាំងស្តង់ចំនួន ២កន្លែង ផ្សេងគ្នា ទី(១) នៅទីធ្លាក្រុងរណបជ្រោយចង្វារ OCIC ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣ រៀបចំដោយក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ សហការជាមួយអង្គការដៃគូរួមមាន KHANA, MHC, CWPD & AHF និង ទី(២)នៅរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ




សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

ចាប់ពី ថ្ងៃទី២៦ ដល់ ថ្ងៃទី២៨ ឆ្នាំ២០២៣ ដែលរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សហការជាមួយក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការដៃគូ KHANA, AHF, MHC, CWPD & RHAC ។

ជាផែនការតាមការគ្រោងទុកក្រុមការងារក្រុមការងារមជ្ឈមណ្ឌលជាតិ និងក្រុមអង្គការដៃគូពាក់ព័ន្ធបានត្រៀមទុកនូវកម្លាំងសម្រាប់ចុះអនុវត្តយុទ្ធនាការ សម្ភារ និងខិត្តប័ណ្ណអប់រំផ្សព្វផ្សាយសម្រាប់សកម្មភាពនៃការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នេះនូវស្រោមអនាម័យ ចំនួន ១០០,០០០ ស្រោម ទឹករំអិល ចំនួន ៣០,០០០ កញ្ចប់ ខិត្តប័ណ្ណផ្សព្វផ្សាយអំពីការការពារ និងធ្វើតេស្ត ឈាមចំនួន ២០,០០០ សន្លឹក ខិត្តប័ណ្ណស្តីពី PrEP ចំនួន ២០,០០០ សន្លឹក អាវយឺត ចំនួន ១,០០០ អាវ និងខិត្តប័ណ្ណអប់រំផ្សេងៗមួយចំនួនប្រមាណចំនួន២០,០០០ សន្លឹក ទៀត ។

## I. <u>ទីតាំងស្តង់អប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍នៅតំបន់ទីក្រុងរណបជ្រោយចង្វារ(OCIC)</u>

- **សមាសភាពក្រុមការងារ៖**
  - មន្រ្តីមជ្ឈមណ្ឌលជាតិចំនួន ០៧ រូប
  - ក្រុមការងារ KHANA ០៤ រូប
  - ក្រុមការងារ MHC ១០ រូប
  - ក្រុមការងារ CWPD ០៩ រូប
  - ក្រុមការងារ WNU ១០ រូប
  - ក្រុមការងារកម្មវិធីអេដស៍មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ០៣ រូប




- **សកម្មភាព៖**

សម្រាប់ថ្ងៃទី៣នៃយុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នៃពិធីបុណ្យអុំទូកបណ្តែតប្រទីប និងសំពះព្រះខែ អកអំបុកបានបន្តយ៉ាងរលូនដោយមានការចូលរួមដោយមន្រ្តីជំនាញមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សហការណ៍អង្គកាដៃគូពាក់ព័ន្ធរួមមាន(KHANA, MHC, CWPD) នៅទីតាំងទីក្រុង



វណបជ្រោយចង្វារ(OCIC) ដែលជាកន្លែងកីឡាករស្នាក់នៅដោយបានបែងចែកជាក្រុមចល័តសម្រាប់ចុះផ្សព្វផ្សាយអប់រំដោយផ្ទាល់ដល់កីឡាករអុំទូក និងប្រជាពលរដ្ឋទូទៅនៅទីតាំងនោះក្នុងអំពីការបង្ការការចម្លងមេរោគអេដស៍ការធ្វើតេស្តរកមេរោគអេដស៍ការចែកជូនអាវយឺត ចែកទឹករំអិល និងស្រោមអនាម័យតាមទីតាំងដែលបានចុះផ្ទាល់។ ថ្ងៃទី៣ នេះផងដែលដោយមានការស្នើសុំពីប្រធានគណកម្មការអចិន្ត្រៃមកពីក្រសួងអប់រំ យុវជន និងកីឡា នូវអាវយឺតចំនួន ១០០ អាវ សម្រាប់ ចែកជូនដល់ក្រុមការងាររបស់គាត់ក្នុងជួយផ្សព្វផ្សាយបន្តដោយយោងតាមស្ថានភាពស្តុកអាវយឺតនៅស្តង់ OCIC មានចំនួនគ្រប់គ្រាន់ ក្រុមការងារក៏បានធ្វើការផ្តល់ជូនតាមសំណូមពរទៅតាមចំនួនដែលបានស្នើសុំ។

## II. ទីតាំងស្តង់អប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍នៅរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ

- **សមាសភាពក្រុមការងារៈ**
  - មន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
  - មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ០៥ រូប
  - ក្រុមការងារ KHANA ០៤ រូប
  - ក្រុមការងារ MHC ១០ រូប
  - ក្រុមការងារ CWPD ០៧ រូប
  - ក្រុមការងារ AHF ១៥ រូប (OW ១០ រូប)
  - ក្រុមការងារ WNU ១០ រូប
  - ក្រុមការងារកម្មវិធីអេដស៍មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ០៣ រូប
- **សកម្មភាពៈ**

សម្រាប់ថ្ងៃទី៣ ទីតាំងរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំក៏បានបន្តយ៉ាងសកម្មនូវយុទ្ធនាការអប់រំផ្សព្វផ្សាយស្តីអំពីមេរោគអេដស៍ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នេះដោយមានការចូលរួមដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រួមជាមួយមន្ត្រីជំនាញមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍សើស្បែក និងកាមរោគ និងសហការណ៍ពីអង្គការដៃគូពាក់ព័ន្ធរួមមាន(KHANA, AHF, MHC, CWPD & RHAC) នៅទីតាំងរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំគឺជាកន្លែងកីឡាករដើរលេងកំសាន្ត ជាពិសេសពេលរាត្រីដោយក្រុមការងារបានធ្វើការបែងចែកជាក្រុមចល័តសម្រាប់ចុះផ្សព្វផ្សាយអប់រំដោយផ្ទាល់ដល់កីឡាករអុំទូក និងប្រជាពលរដ្ឋទូទៅស្តីពីការបង្ការការចម្លងមេរោគអេដស៍ ការធ្វើតេស្តរកមេរោគអេដស៍ការចែកជូនអាវយឺត ចែកទឹក រំអិល





និងស្រោមអនាម័យតាមទីតាំងនីមួយៗដោយឥតគិតថ្លៃ។ ថ្ងៃនេះផងដែលក្រុមការងារបានធ្វើបទសម្ភាសន៍ជាមួយស្ថានីយ៍ទូរទស្សន៍អប្សរា និងក្រុមសារព័ត៌មានបានចុះយកព័ត៌មាន និងចុះផ្សាយនូវសកម្មភាពនៃយុទ្ធនាការនេះផងដែលដើម្បីចូលរួមចំណែកបន្ថែមក្នុងការពង្រីកការផ្សព្វផ្សាយខ្លឹមសារអប់រំក្នុងអំឡុងព្រឹត្តិការណ៍នេះ។



នាពេលល្ងាចថ្ងៃដដែលក៏មានការបន្តរៀបចំការប្រគុំតន្ត្រីក្រោមការរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការដៃគូដើម្បីពង្រីកសារនៃការអប់រំទាំងនេះពេលរាត្រី និងបញ្ជ្រាបការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍ និងជំងឺ អេដស៍ និងជាស់តឿនក្រើនរំឭកដល់កីឡាករអុំទូក និងបងប្អូនជនរួមជាតិទាំងអស់ សូមឱ្យប្រុងប្រយ័ត្នបង្ការខ្លួនជាប់ជានិច្ចកុំឱ្យឆ្លងមេរោគអេដស៍ព្រោះជំងឺអេដស៍ និងសុំឱ្យប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០% នៅពេលមានដៃគូក្រៅ និងប្រញាប់ទៅធ្វើតេស្តឈាមរកមេរោគអេដស៍ប្រសិនបើសង្ស័យថាមានផ្ទុកមេរោគអេដស៍ ដើម្បីឆាប់បានទៅទទួលសេវាផ្តល់ប្រឹក្សា និងទទួលឱសថពន្យារជីវិតអោយបានកាន់តែឆាប់រហ័សក្នុងថ្ងៃតែមួយ។



សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

# សមិទ្ធផលសង្ខេបរួមទាំងពីរទីតាំងចាប់ពីថ្ងៃទី ២៥ ដល់ ២៧ ខែ វិច្ឆិកា ឆ្នាំ ២០២៣

| ល.រ | សកម្មភាពទាំង ២ទីតាំង | ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | បានអប់រំផ្សព្វផ្សាយ | ២,៥៤៦ នាក់ | ៥,១១៣ នាក់ | ៤,៩៩៥ នាក់ | |
| ២ | បានធ្វើតេស្តឈាម | ១៣ នាក់ | ៤៣ នាក់ | ៣៦ នាក់ | |
| ៣ | លទ្ធផលអេដស៍តេស្តប្រតិកម្ម | ០ នាក់ | **២ នាក់** | **២ នាក់** | |
| ៤ | លទ្ធផលស្វាយតេស្តប្រតិកម្ម | ០ នាក់ | **២ នាក់** | **១ នាក់** | |
| ៥ | បានចែកស្រោមអនាម័យ | ១២,៩៨៤ ស្រោម | ២៩,៤៨៧ ស្រោម | ១៣,១៥១ ស្រោម | |
| ៦ | បានចែកទឹករំអិល | ៤,៥៥៨ កញ្ចប់ | ៧,០៣៤ កញ្ចប់ | ២,១៨៦ កញ្ចប់ | |
| ៧ | បានចែកខិត្តប័ណ្ណ | ២,៦៨៧ សន្លឹក | ៥,២៦៩ សន្លឹក | ៦,២០៣ សន្លឹក | |
| ៨ | បានចុះឈ្មោះសេវា PrEP | ០ នាក់ | ១ នាក់ | ០ នាក់ | |
| ៩ | អាវយឺតសម្រាប់អប់រំ | ២៥០ អាវ | ៤០០ អាវ | ១៥០ អាវ | |

ថ្ងៃច័ន្ទ ១៥កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០២៣

| បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | ធ្វើសេចក្តីរាយការណ៍ដោយ |
|---|---|---|
| សាស្ត្រាចារ្យ ជ.អ៊ឹក វិជ្ជា | វេជ្ជបណ្ឌិត ង៉ូវ បូរ៉ា | លោក ចំរើន បូរ៉ា |

សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក